**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**

**ប្រចាំសហព័ន្ធរុស្ស៊ី**

**ស្ថានតំណាងពាណិជ្ជកម្ម**

**លេខ** ០៦.០១ RCM

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** : របាយការណ៍ស្ថានតំណាងពាណិជ្ជកម្ម ប្រចាំសហព័ន្ធរុស្ស៊ី ឆ្នាំ ២០០៨

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេតាជ្រាបអំពីស្ថានភាព សេដ្ឋកិច្ច ពាណិជ្ជកម្មសហព័ន្ធរុស្ស៊ី ឆ្នាំ ២០០៨ និងសកម្មភាពការងាររបស់ស្ថានតំណាងពាណិជ្ជកម្ម ឆមាសទី ២ ឆ្នាំ២០០៨ នេះ មានដូចតទៅ ÷

**១. ស្ថានភាពទូទៅ**

ក្រោយពីវិបត្តិសេដ្ឋកិច្ចឆ្នាំ១៩៩៨ រុស្ស៊ីបានធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយការឆ្លងកាត់វិបត្តិពីមួយទៅមួយយ៉ាងលំបាករហូតធ្វើអោយមានភាពល្អប្រសើរបន្តិចម្តងៗដែល ឆ្នាំ២០០៣ កំណើនសេដ្ឋកិច្ចជាមធ្យមមានចំនួន ៧% ក្នុងនោះ FDI មានកំណើនចំនួន ១០% ចំណូលប្រជាជនកើន១២% ជីវភាពប្រជាជនកម្រិតក្រីក្រធ្លាក់ចុះ កម្រិតមធ្យមកើនឡើង។ រូបិយប័ណ្ណបរទេសកើនពីកំរិតសូន្យនៅ ឆ្នាំ១៩៩៨ ដល់ចំនួន ៤៨០ពាន់លានដុល្លារអាមេរិកនៅ ឆ្នាំ២០០៨ ហើយជាប់ ចំណាត់ថ្នាក់ទី ៣ ជាប្រទេសដែលមានធនបំរុងធំនៅផ្សារអន្តរជាតិ។ រុស្ស៊ីបានប្រើប្រាស់ថវិការដែលមានទៅសងបំណុលសភាពសូវៀតនៅ **Paris Club & IMF** ។

ក្នុងរបបគ្រប់គ្រងលោក **Vladimir Putin** អតីតប្រធានាធិបតី រុស្ស៊ីនា ឆ្នាំ ២០០១ ដល់ ២០០៧ លោកបានធ្វើការកែរទម្រង់ប្រព័ន្ធសេដ្ឋកិច្ចជាច្រើនដែលមាន ការកែទម្រង់ប្រព័ន្ធធនាគារច្បាប់ដីធ្លី កម្លាំងពលកម្ម ។ ហើយជាលទ្ធផល កំណើន FDI កើនដល់ ៣០.០០០ លានដុល្លារអាមេរិក ។ការនាំចេញឈើប្រេង និងឧស្ម័នមានចំនួន ៨០% នៃការនាំចេញសរុប។ ចំណូលពីប្រេង និងឧស្ម័នមានទឹកប្រាក់ចំនួន ១៤៤ពាន់លានដុល្លារអាមេរិក។ វិស័យថាមពលមានកំណើនខ្ពស់ និងជាប់ចំណាត់ថ្នាក់ទី ៤ ជាប្រទេសមានទីផ្សារថាមពលធំក្នុងពិភពលោក។ វិស័យ IT កំណើនមានចំនួន ២៥%មានក្រុមហ៊ុនធំៗចំនួន ២០ ក្នុងនោះក្រុមហ៊ុនបរទេសមានចំនួន ៣។


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**

ឆ្នាំ ២០០៨ រុស្ស៊ីទទួលបានផលជាវិជ្ជមានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម ដោយទទួលបាននូវកំណើនសេដ្ឋកិច្ចដែលមានចំនួន ១៣.៣% នៃ GDP នេះជាលទ្ធផលនៃការកើនឡើងការនាំចេញ ប្រេង និងឧស្ម័នជាច្រើន និងបានជាប់ចំណាត់ថ្នាក់លេខ ៣០ ក្នុងចំណោមប្រទេសអ្នកនាំចេញធំចំនួន ១២៥ ។ រុស្ស៊ីក៏ទទួលបានកិច្ចព្រមព្រៀងទ្វេភាគីពីទីផ្សារនាំចេញនិងបណ្តាប្រទេសដៃគូរជាច្រើនតាមរយៈការចរចារចូល**WTO**និងទទួលបានភាពអនុគ្រោះពាណិជ្ជកម្ម **GSP** ជាមួយនិងបណ្តាប្រទេស **EU & US** ដែរ ។

## ២~វិបត្តិសេដ្ឋកិច្ច

ខែ កក្កដា ឆ្នាំ ២០០៨ ថ្លៃប្រេងរុស្ស៊ីចាប់ផ្តើមធ្វើការធ្លាក់ចុះ ធនាគាររុស្ស៊ីជាច្រើនដួលរលំក្រុមហ៊ុនរុស្ស៊ីចំនួន ៩០% បានធ្វើការកាត់បន្ថយកំលាំងពលកម្មចំនួនជាងពាក់កណ្តាលនៃចំនួនមនុស្សធ្វើការងារ ។ ក្នុងទីផ្សារទំហំនៃការទិញថយចុះចំនួន ១០-២០% អតិផរណាមានចំនួន ១៣.៣% ការហូរចេញរូបិយប័ណ្ណបរទេសមានចំនួន ៥០ពាន់លានដុល្លារអាមេរិក ។ក្រុមហ៊ុនប្រេងកាតរុស្ស៊ីបានធ្វើការកាត់បន្ថយការនាំចេញប្រេងក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៨ ចំនួន ១.៥លានតោន ដែលមានចំនួនប្រហែលនឹង ៣៥០ពាន់ barrels ក្នុង១ថ្ងៃ ។ រុស្ស៊ីអាចនិងធ្វើការកាត់បន្ថយការផលិតប្រេងកាតពី **៣០០ -៣២០ពាន់ barrels** ក្នុង១ថ្ងៃ ។ កិច្ចសហការនិងបណ្តាប្រទេស **OPEC** បានកាត់បន្ថយការផលិតប្រេងកាត ចំនួន **២លាន barrels** ក្នុង១ថ្ងៃ ។

ដើម្បីបន្តទ្រទ្រង់ដំណើរការសេដ្ឋកិច្ចរដ្ឋាភិបាលបានផ្តល់៣២៦.៣០០លានរូប្ល ដោយធ្វើការបែងចែក ៧០ ពាន់លានរូប្លសំរាប់ធនាគារកសិកម្ម ១៨.១០០ លានរូប្លសំរាប់សហគ្រាសកសិឧស្សាហកម្ម ក្រុមហ៊ុនអកាសចរណ៍ ៣២ពាន់លានរូប្លសំរាប់ក្រុមហ៊ុនផលិតរថយន្ត ៣៩ពាន់លានរូប្លសំរាប់ឧស្សាហកម្មនាំចេញ ៦ពាន់លានរូប្ល SME ៦២០០លានរូប្ល ផ្សារពលកម្ម ៤៣៧០០លានរូប្ល ។

## ៣~WTO

ខែ មករា ឆ្នាំ ២០០៩ រុស្ស៊ីនិងបន្តកិច្ចប្រជុំអន្តរភាគី WTO ។ ក្នុងឆ្នាំ ២០០៨ រុស្ស៊ីបានបញ្ចប់ កិច្ចប្រជុំអន្តរភាគី ។ មូលហេតុយឺតយ៉ាវដំណើរការប្រជុំចូលជាសមាជិកដោយសារការកើតឡើងផ្ទួន១គ្នានូវព្រឹត្តការណ៍សំខាន់១ ដែលមានការផ្លាស់ប្តូរថ្នាក់ដឹកនាំកំពូលប្រទេសអាមេរិក ការកើតឡើងវិបត្តិនៅ **Caucasia** និងទីបំផុតវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ។ អ្នកជំនាញការរុស្ស៊ីជាច្រើនបានធ្វើការប៉ាន់ស្មានថា រុស្ស៊ីអាចនិង ចូលជាសមាជិក **WTO**នៅឆ្នាំ ២០១០ ។ បញ្ហាដែលនៅសេសសល់ចំបងក្នុងការចរចាទាក់ទងទៅនិងគោលនយោបាយធំ១៣ដែលមាន ១-ការឧបត្ថម្ភធនវិស័យកសិកម្ម ២-ពន្ធឈើមូល៣-កិច្ចការសហគ្រាសរដ្ឋ និងបញ្ហាបច្ចេកទេសមួយចំនួនទៀត ។ ថ្នាក់ដឹកនាំរុស្ស៊ីថ្លែងអោយដឹងថា រហូតដល់ពេលចូលជាសមាជិក WTO និងមិនបន្តអនុវត្តកាតួពកិច្ចចាស់ ហើយមិនទទួលយកកាតួពកិច្ចបន្ថែមទៀត ។ នៅដើមឆ្នាំ ២០០៩ រុស្ស៊ីបានសំរេចបង្កើនពន្ធនាំចូលបណ្តោះអាសន្នរយៈពេល ៩ខែលើ លោហធាតុ ពី ៥% ដល់ ២០% ពន្ធរថយន្ត រយៈពេល ៣ឆ្នាំ ពី ៤៨ ទៅ ៥៤% ។វិធានការនេះគឺការពារទៅនឹងទីផ្សារក្នុងស្រុករុស្ស៊ីដើម្បីការពារនិងការនាំចូលទំនិញច្រើនលើសលប់ និង មានតំលៃថោកពីបណ្តាប្រទេសអាស៊ីពិសេសប្រទេសចិន ដើម្បីតបតទៅនឹងសម្ពាធនៃការយឺតយ៉ាវចរចាចូល **WTO** ។


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: **+7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**
Trade Representative MOC Moscow, Russian Federation 

## ៤-ពាណិជ្ជកម្ម

ឆ្នាំ ២០០៨ សមតុល្យពាណិជ្ជកម្មមានចំនួន ៩៨.៩០០ លានដុល្លារអាមេរិក កើន ចំនួន ២៩.៨%ធៀបនិង ឆ្នាំ ២០០៧។ រយៈពេល ១១ខែដើមឆ្នាំ ការផ្លាស់ប្តូរពាណិជ្ជកម្មមាន ៦៨៥ពាន់ លានដុល្លារអាមេរិក កើន ៣៩.៦% ក្នុងនោះជាមួយប្រទេសអតីតសហភាពសូវៀតមាន ១០០.៥០០ លានដុល្លារអាមេរិក និងប្រទេសផ្សេងទៀតមាន ៥៨៤.៧០០ លានដុល្លារអាមេរិក។ ទំនិញនាំចេញថាមពលមាន ៧០% ទំនិញនាំចេញសំខាន់ផ្សេងទៀតមាន លោហធាតុ ក្រដាសCellulos រថយន្ត ជី ស្បៀង។ល។ ទំនិញនាំចូលសំខាន់មាន សំភារៈសាងសង់ រថយន្តដឹកជញ្ជូន សំភារៈ Optic ។

វាយនភ័ណ្ឌ និង សំលៀកបំពាក់រុស្ស៊ី ជាទីផ្សារធំមួយក្នុងចំណោមទីផ្សារធំក្នុងពិភពលោក នេះគឺដោយសារ វិសាលភាពនៃចំនួនប្រជាជនរុស្ស៊ីដែលមានចំនួន ១៤៧លាននាក់។ បច្ចុប្បន្នគេសង្កេតឃើញមានទីផ្សាររុស្ស៊ីដែលមានគុណភាពខ្ពស់ជាច្រើន នេះគឺដោយសារការចាប់ដៃគូរបស់ក្រុមហ៊ុនក្នុងស្រុក និងក្រៅប្រទេសដែលមានដូចជា ប្រទេស អាមេរិក អ៊ីតាលី អាល្លឺម៉ង់ ដើម្បីទទួលបានការកែរលំអគុណភាព។ ក្នុង រយៈពេល **Crisis** រុស្ស៊ីចាប់ផ្តើមធ្វើការទិញសំលៀកបំពាក់ក្នុងស្រុកដែលមិនមានតំលៃខ្ពស់ ។តែ ដោយសារការផ្គត់ផ្គង់ក្នុងស្រុកមានចំនួនតែ ៤០% នៃទីផ្សារតំរូវអោយរុស្ស៊ីបន្តធ្វើការនាំចូលសំលៀកបំពាក់និងស្បែកជើងជាច្រើនទៀត។ តំលៃលក់សំលៀកបំពាក់ទីផ្សារក្នុងស្រុកមួយឆ្នាំមានចំនួន ៨៥០ពាន់ លានដុល្លារអាមេរិកឆ្នាំ ២០០៨ រៀងរាល់ឆ្នាំកំណើនទីផ្សារលក់មានចំនួន ២៥-២៧% ។

វិស័យកសិកម្ម ក្នុងនោះស្ថានភាពដាំដុះស្រូវមានកំណើនគួរកត់សំគាល់ បរិមាណដីដាំដុះស្រូវនៅប្រទេសរុស្ស៊ីកើនពីចំនួន ១៦៥-១៧០ ពាន់ហិកតា នៃផ្ទៃដីដាំដុះគ្រាប់ធញ្ញជាតិសរុបដែលមានចំនួន ៧៥០ពាន់ហិកតា តំបន់ផលិតអង្ករមានចំនួន ៥ និងក្រុមហ៊ុនផលិតអង្ករធំពុមានចំនួន ៣ ។ ការប្រើប្រាស់អង្ករក្នុងរុស្ស៊ីមានចំនួន ៤១%នៃការប្រើប្រាស់គ្រាប់ធញ្ញជាតិសរុប ។ក្នុងឆ្នាំ ២០០៨តំរូវការអង្កររុស្ស៊ីមាន ៦៥០ពាន់តោន ក្នុងនោះ អង្ករផលិតក្នុងស្រុកមានចំនួន ៤៧០ពាន់តោន។ ក្នុងទីផ្សារបរិមាណអង្ករនាំចូលមានចំនួន ២៨០-៣០០ពាន់តោនធៀបនិង ២០០៧មានចំនួន ២៣២ ពាន់តោន កើនឡើងតំរូវការអង្ករគុណភាពខ្ពស់ ប្រភេទអង្ករក្នុងទីផ្សាររុស្ស៊ីមាន អង្ករ គ្រាប់វែង គ្រាប់មូល អង្ករស្អិត អង្ករក្រអូប។ ថ្លៃអង្ករ ក្នុងទីផ្សាររុស្ស៊ីកើនចំនួន ៦៦% រយៈពេលខែមីនាឆ្នាំ២០០៧-មីនាឆ្នាំ២០០៨និងមានតំលៃចំនួន ៥៤៦ដុល្លារអាមេរិកក្នុង១តោន។ ក្នុងរយៈពេលនៃវិបត្តិទីផ្សារអង្ករអន្តរជាតិការនាំចូលអង្ករនៅរុស្ស៊ីធ្លាក់ចុះចំនួន១៣.៩០០ -៩០០០ តោន មានតំលៃចំនួនជាង ១០០០ដុល្លារអាមេរិកក្នុង១តោន។ តំលៃអង្ករនាំចូលខ្ពស់ដោយសារវិធានការរបស់រដ្ឋាភិបាលក្នុងការបន្ថែមពន្ធនាំចូលដើម្បីទប់ស្កាត់ការ នាំចូលអង្ករអន់គុណភាព និងមិនឆ្លើយតបនិងស្តង់ដារអង្កររុស្ស៊ី។

## ៥-នយោបាយពាណិជ្ជកម្ម

ការអនុវត្តគោលនយោបាយពាណិជ្ជកម្មរុស្ស៊ីឈរលើមូលដ្ឋាននៃការធ្វើសេរីភាវូបនីយកម្ម។ បច្ចុប្បន្ន សហគ្រាសនិងក្រុមហ៊ុនត្រូវបានអនុញ្ញាតអោយធ្វើពាណិជ្ជកម្មគ្រប់ផលិតផលទាំងអស់។ អាជ្ញាប័ណ្ណនាំចូលតម្រូវមានតែលើមុខទំនិញចាំបាច់មួយចំនួន។ អត្រាពន្ធឈរលើគោលនយោបាយ **Harmonizing Commodity & Coding System(HS)** ។ គ្រប់ទំនិញដឹកជញ្ជូនឆ្លងកាត់ត្រូវធ្វើការបំពេញប្រតិវេទន៍គយ ក្នុងរយៈពេល ១៥ថ្ងៃក្រោយទំនិញមកដល់និងត្រូវធ្វើការបង់ពន្ធ ។ក្រៅពីពន្ធនាំចូលគ្រប់មុខទំនិញ និងសេវាកម្មត្រូវបង់ពន្ធ VAT បន្ថែមទៀត។ VAT ត្រូវបានកាត់បន្ថយពី ២០%


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**
Trade Representative MOC Moscow, Russian Federation

មក ១៨% ។ VAT ត្រូវបានលើកលែងចំពោះទំនិញដែលមានអត្រា VAT ទាបជាង ១០% ដូចជា អាហារ សំភារៈកូនក្មេង និងចំពោះទំនិញ-សេវាកម្មសំរាប់នាំចេញបន្ត ។ ពន្ធនៃការលក់ក្នុងតំបន់ត្រូវបានលប់ចោល ។

ទំនិញនាំចូល ដែលមានដូចជាទំនិញប្រើប្រាស់ទាមទារអោយស្របទៅនិងស្តង់ដាសុវត្ថិភាពរុស្ស៊ី ។ វិញ្ញាប័នប័ត្រ ដែលគេទទួលស្គាល់ទូទៅ ហើយដែលគយព្រំដែនតំរូវអោយមានគឺ **GOSTR Certificate of Company(CoC)** ដែលចេញដោយ**Gostandard(Gost)** រុស្ស៊ី ។

## ៦_ជំនួយ

រដ្ឋាភិបាលរុស្ស៊ីមានគំរោងបង្កើនជំនួយចំនួន ២ដង ជារៀងរាល់ឆ្នាំដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានទឹកប្រាក់ចំនួន ៤០០-៥០០ លានដុល្លារអាមេរិក នៅឆ្នាំ ២០១១ ។ ឆ្នាំ ២០០៣-២០០៥ ជំនួយមានទឹកប្រាក់ចំនួន ៥០-៦០ លានដុល្លារអាមេរិក ឆ្នាំ ២០០៧-២០០៨ មាន ២១០-២២០ លានដុល្លារអាមេរិក ។ គំរោងជំនួយនេះមានសារៈសំខាន់សំរាប់រុស្ស៊ី ដោយអោយរុស្ស៊ីមានសំឡេងក្នុងការចូលរួមចំណែកដោះស្រាយបង្កើតប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ និងប្រព័ន្ធសន្តិសុខ ។ គោលបំណង ជំនួយ គឺ : ១-ប្រឆាំងជំងឺឆ្លង ២- កាត់បន្ថយភាពក្រីក្រ ៣-លើកកំពស់ក្របខ័ណ្ឌសិក្សា និងអប់រំក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ រុស្ស៊ីជួយប្រទេស កំពុងអភិវឌ្ឍន៍ដែលមាន **Tajackistan, Kirgyzia** ប្រទេសក្រីក្រដែលមាន **Efiopy Bangladesh**. ។

## ៧_ទំនាក់ទំនងពាណិជ្ជកម្ម រុស្ស៊ី_កម្ពុជា

**<u>Foreign Trade of the Russia - Kingdom of Cambodia in 2007</u>**
**US $ million**

| 2007 | Turnover | Export | Import |
|---|---|---|---|
| **Total** | **29** | **11** | **18** |

**<u>Foreign Trade of the Russia and the Kingdom of Cambodia in 2008</u>**
**<u>(Preliminary statistics before 23.01.2009)</u>**

US $ million

| Commodity classification | Import of Russia | Export of Russia | Foreign Trade |
|---|---|---|---|
| **Total** | **25 259 366** | **8 628 816** | **33 888 182** |
| Included: | | | |
| 29 organic chemical compounds | 0 | 411 | 411 |
| 32 tan or dye extracts; tan or dye compounds; all the sorts of dye substances; paints and lacquers; printer ink, Indian ink | 0 | | |
| 34 soup, washing active organic substances, lubricants, artificial and finished wax, compounds for cleaning or polishing, candles, plastics for modeling, «teeth wax» and compounds for teeth based on gypsum | 0 | 9 497 | 9 497 |


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**

| | | | |
|---|---|---|---|
| 38 others chemical products | 0 | 1504 | 1 504 |
| 39 plastic and articles in plastic | 14 | 3 269 | 3 283 |
| 40 caoutchouc, rubber products | 0 | 22 006 | 22 006 |
| 42 articles from leather; saddles and harness; traveling accessories; handbags for women and analogous products from animals guts (except the fiber of fibroin or silkworm) | 91 | 0 | 91 |
| 46 straw and Alfa articles, baskets | 29 345 | 0 | 29 345 |
| 48 paper, cardboard and articles in paper and cardboard | 0 | 2 884 312 | 2 884 312 |
| 49 books, papers, reproductions and others printing articles; manuscripts, plans | 45 098 | 3 849 320 | 3 894 418 |
| 52 cotton | 0 | 34 | 34 |
| 54 chemical filament; flat and analogous filament from chemical textile materials | 0 | 120 | 120 |
| 61 cloth and accessory, fabric knitwear, hand-made knitting | 14 636 990 | 0 | 14 636 990 |
| 62 cloth and accessory, except fabric and hand-made knitting wear | 9 236 799 | 0 | 9 236 799 |
| 63 other finished textile; sets; clothing and textile articles second hand | 0 | 12 | 12 |
| 64 footwear, gaiters and analogous articles; theirs parts | 1 297 819 | 0 | 1 297 819 |
| 68 articles from stone, gypsum, cement, asbestos, mica or from analogous materials | 0 | 4 | 4 |
| 70 glass or glass articles | 0 | 70 | 70 |
| 73 articles from nonferrous metals | 0 | 4 110 | 4 110 |
| 76 aluminum and articles from it | 0 | 5 322 | 5 322 |
| 82 instruments, devices, knives, spoons, forks from non precious metals | 0 | 53 | 53 |
| 83 other articles from non precious metals | 0 | 50 | 50 |
| 84 nuclear reactive boilers, equipment, mechanical installations, their parts | 668 145 | 668 145 | 668 145 |
| 85 electrical machines and equipment, theirs parts; sound apparatus for register and reproduce, installations for register and reproduce the TV picture and sound, their parts | 0 | 11 697 | 11 697 |
| 87 ground transports, except movable railroad and tramway, their parts | 0 | 257 694 | 257 694 |
| 88 flying and cosmic apparatus | 0 | 234 300 | 234 300 |
| 90 instruments and apparatus: optical, photographical, cinematographic, measuring, control, medical or surgical; their parts | 0 | 52 566 | 52 566 |
| 94 furniture; clothes mattress, mattress basis, cushions and analogous, furniture stuffing implement; lamps and illuminated equipment, non mentioned in another place or non included; light sign boards including name or address and analogous articles; assembling | 13 042 | 24 | 13 066 |


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**

| | | | |
|---|---|---|---|
| constructions | | | |
| 95 toys, sport fittings; their parts | 168 | 112 800 | 112 068 |

<u>ប្រភព</u> **:** លិខិតលេខ ១៦-៤១/ ២៨២៣ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៩ របស់ **Federal Customs Service**

ឆ្នាំ ២០០៨ ការផ្លាស់ប្តូរពាណិជ្ជកម្មរុស្ស៊ីកម្ពុជាមានទឹកប្រាក់ចំនួន ៣៤លានដុល្លារអាមេរិក កើនឡើងចំនួន ១៧% ធៀបនិងឆ្នាំ ២០០៧ ដែលមានទឹកប្រាក់ចំនួន ២៩ លានដុល្លារអាមេរិក។

ការនាំចេញពីរុស្ស៊ីទៅកម្ពុជាមានទឹកប្រាក់ចំនួន ៩ លានដុល្លារអាមេរិកធ្លាក់ចុះចំនួន ១៨% ធៀបនិងឆ្នាំ ២០០៧ ដែលមានទឹកប្រាក់ចំនួន ១១ លានដុល្លារអាមេរិក។ ទំនិញនាំចេញសំខាន់ៗមាន សៀវភៅ គ្រឿងសំភារៈ Printing សំភារៈ Optic ។

ការនាំចូលពីកម្ពុជាទៅរុស្ស៊ីមានទឹកប្រាក់ចំនួន ២៥ លានដុល្លារអាមេរិកកើនឡើងចំនួន ៣៩% ធៀបនិងឆ្នាំ ២០០៧ ដែលមានទឹកប្រាក់ចំនួន ១៨ លានដុល្លារអាមេរិក។ ទំនិញនាំចេញសំខាន់ៗមាន សំលៀកបំពាក់ ស្បែកជើង។

**-បំណុលរុស្ស៊ី-កម្ពុជា**

ថ្មីៗនេះក្រសួងសេដ្ឋកិច្ចរុស្ស៊ីប្រកាសអោយដឹងថា រុស្ស៊ី និងកម្ពុជាអាចនិងបន្តការពិភាក្សាបំណុលនៅឆ្នាំ ២០០៩។ បំណុលកម្ពុជាជំពាក់រុស្ស៊ីមានទឹកប្រាក់ចំនួន ១៥០០ លានដុល្លារអាមេរិក។ ខែ វិច្ឆិកា ឆ្នាំ២០០៨អ្នកនាំពាក្យសភាជាន់ទាបរុស្ស៊ីប្រកាសពីលទ្ធផលទស្សនកិច្ចនៅកម្ពុជាថា រុស្ស៊ីបានពិភាក្សានិងថ្នាក់ដឹកនាំកម្ពុជាថា រុស្ស៊ីអាចនិងធ្វើការលប់បំណុល មួយចំនួនរបស់កម្ពុជាដែលមានចំនួន ១៥០០ លានដុល្លារអាមេរិកក្នុងក្របខណ្ឌ **Paris Club** បំណុលផ្សេងទៀតនិងធ្វើការទូទាត់ដោយប្រើការប្រាក់ទាប។

**II – <u>សកម្មភាពស្ថានតំណាងពាណិជ្ជកម្ម</u> :**

**១-<u>ទំនាក់ទំនងស្ថានទូត</u>**

ថ្ងៃទី ៣១ ខែ ធ្នូឆ្នាំ ២០០៨ ចូលរួមក្នុងឱកាសបុណ្យចូលឆ្នាំ សកល ២០០៩។ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៩ ចូលរួមក្នុងឱកាសបុណ្យជាតិ ៧ មករា ។

ផ្តល់ឯកសារជំនួយស្មារតីទំនាក់ទំនងពាណិជ្ជកម្ម កម្ពុជា-រុស្ស៊ី ជូនស្ថានទូតសំរាប់ការប្រជុំ ASEAN នៅមូស្គូ តាមការស្នើសុំពីស្ថានទូត។

**២-ទំនាក់ទំនងស្ថានប័នរុស្ស៊ី**

ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ជួបស្ថាប័នគយរុស្ស៊ី និង ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មរុស្ស៊ីដើម្បីជូនវត្ថុអនុស្សាវរីយ៍ជូនពរបុណ្យចូលឆ្នាំ សកល ២០០៩ ដែលមាន ជូនស្ថាប័នគយ(លោកប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញធ្វើការងារផ្ទាល់និងស្ថានតំណាង)ជូនក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងពាណិជ្ជកម្មរុស្ស៊ី(លោកស្រីប្រធាននាយកដ្ឋាន និងមន្ត្រីការិយាល័យជំនាញ ២ រូបធ្វើការងារផ្ទាល់និងស្ថានតំណាង) ។

នៅថ្ងៃដដែលនេះដែរ តាមការជួបធ្វើការងារនិងលោក Sitnikov ប្រធានការិយាល័យនៃនាយកដ្ឋាន អា


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**

ស៊ី ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចពាណិជ្ជកម្ម បានអោយដឹងថា ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចពាណិជ្ជកម្មបានធ្វើការជ្រើសរើស លោក **Yarochkin** ប្រធាននៃទីភ្នាក់ងារសហពន្ធ **Rostourizm** ជាបេក្ខជននៃប្រធានគណៈកម្មការអន្តរដ្ឋាភិបាល កម្ពុជា-រុស្ស៊ី ។ ក្រសួងនិងបញ្ជូនឈ្មោះនេះទៅក្រសួងការបរទេសរុស្ស៊ីនៅពាក់កណ្តាលខែមករា ឆ្នាំ ២០០៩ ។ករណី ក្រសួងការបរទេសឯកភាព និង បន្តសុំការឯកភាពពីលោកនាយករដ្ឋមន្ត្រីរុស្ស៊ី **Putin** ទៀត ។ ក្រសួងពាណិជ្ជកម្មរុស្ស៊ី បញ្ជាក់ថាដំណើរការនេះត្រូវការពេលវេលា ដែលក្រសួងធ្វើការប៉ាន់ស្មានថាអាចនិងទទួលបានចំឡើយខែ មេសា ឆ្នាំ ២០០៩ ។

### ៣-ទំនាក់ទំនងសហគ្រាសរុស្ស៊ី

កាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៨វេលាម៉ោង ៣រសៀលជួបធ្វើការនិងលោក **Panich Alekcendre Michalovich** នាយកក្រុមហ៊ុន **Mazdaa** ប្រចាំនៅមូស្គូ ។គោលបំណងជំនួប ស្វែងរកដីទំនេរនៅមាត់សមុទ្រសាងសង់ជា សណ្ឋាគារ រម្យនីយដ្ឋាន ដើម្បីទាក់ទាញទេសចរណ៍ ។ លោកមានការចាប់អារម្មណ៍និងអភិវឌ្ឍន៍ **Business** របស់លោកនៅខេត្តកំពត ខែ កុម្ភៈ ឆ្នាំ ២០០៩ តំណាងរបស់លោកនិងទៅសិក្សាទីនោះផ្ទាល់ ។លោកបានសុំជាច្បាប់ផ្សេងៗទៀតទាក់ទងនិងពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ។

កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៨វេលាម៉ោង ៣រសៀលជួបធ្វើការនិងលោក **Babak Andrey** ប្រធានហ៊ុន **Kambey.ltd** រុស្ស៊ី ។ គោលបំណងជំនួប ស្វែងយល់ពីទីផ្សារត្រីនៅកម្ពុជា ។ ក្រុមហ៊ុនមានបំណងចង់ទិញដីដើម្បីសាងសង់ជារោងចក្រកែច្នៃត្រី និងនាំចេញទៅរុស្ស៊ី ។ លោកមានគំរោងមកទស្សនកិច្ចកម្ពុជានៅចុងខែ កុម្ភៈ ឆ្នាំ២០០៩ ។

កាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨វេលាម៉ោង ៣រសៀលជួបធ្វើការនិងលោក **Sergey Nicolay Volkov** ប្រធានក្រុមជំនាញសហគ្រាស **OJSC 'INTER RAOUES"** រុស្ស៊ី គោលបំណងជំនួប ចង់ទទួលបានពត៌មានស្តីពីគំរោងកសាងវ៉ារីអគ្គិសនី ផលិតត្បូងថ្ម និងឧស្ម័ន នៅកម្ពុជា ដោយចង់សហការក្នុងល័កខណ្ឌ **BOO (build-own-operate)** ។

### III – ទិសដៅការងារស្ថានតំណាងពាណិជ្ជកម្មឆ្នាំ ២០០៩

ក្នុងឆ្នាំ ២០០៩ នេះ ការងារដែលស្ថានតំណាងពាណិជ្ជកម្មត្រូវអនុវត្តបន្តមាន :

១-ពង្រឹងពង្រីកទំនាក់ទំនង និងស្ថាប័នគយរុស្ស៊ី និង ក្រសួង អភិវឌ្ឍន៍សេដ្ឋកិច្ចពាណិជ្ជកម្មរុស្ស៊ីដោយបង្កើនការជួបផ្លាស់ប្តូរពតិមានសេដ្ឋកិច្ចពាណិជ្ជកម្ម និងសំរួលច្រកចូលទីផ្សារទៅវិញទៅមក ។

២- ស្វែងរក និងបង្កើនការចូលរួមពិព័រណ៍ពាណិជ្ជកម្មដែលផ្តល់ផលប្រយោជន៍សំរាប់ទីផ្សារកម្ពុជាមានពិព័រណ៍ ខោអាវ ស្បែកជើង កាបូប ផលិតផលកសិកម្ម ។

៣-បង្កើនការផ្តល់ជូនពតិមានស្តីពី **Cambodian-Russian trade regulation & trade preference** ។

៤- សិក្សា និងស្វែងរក **Russian Garment contributor** នៅតាមតំបន់រុស្ស៊ី ។

៥- ជំរុញ **Trade mission** កម្ពុជា-រុស្ស៊ី ។



17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**

៦- បន្តតាមដានបញ្ហានៃការចូលជាសមាជិក WTO របស់រុស្ស៊ី ។

៧- បន្តតាមដានបញ្ហានៃការរៀបចំសម័យប្រជុំអន្តរដ្ឋាភិបាលកម្ពុជា-រុស្ស៊ី លើកទី ៥ នៅកម្ពុជា។

អាស្រ័យដូចបានរៀបរាប់ខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពសបំផុត អំពីនាងខ្ញុំ ។

**មូស្គូ. ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩**
**ទីប្រឹក្សាពាណិជ្ជកម្ម**

**កែវ មុត្តធីតា**

**ចម្លងជូន**

-លោកជំទាវខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

-ឯកឧត្តមរដ្ឋលេខាធិការ

-ឯកឧត្តមអនុរដ្ឋលេខាធិការ

-ឯកឧត្តមអគ្គនាយក " ដើម្បីជ្រាបជារបាយការណ៍"

-ឯកសារ-កាលប្បវត្តិ


17393 Moscow, Str.Ak.Pilougina 14-3-781; Mobile: +**7-926 457 89 64**; Email: **rcm_keo@hotmail.com**; Tel/Fax: **+7-495 936 20 18**
Trade Representative MOC Moscow, Russian Federation